# ឯកសិទ្ធរបស់អ្នកក្រោម ឯកសិទិកម្មករបណ្ដោះអាសន្នរដ្ឋម៉ាស្សាជូសេ្សត ដើម្បីនឹងដឹងអំពីច្បាប់

## ទីភ្នាក់ងារជួយរកការងារត្រូវតែផ្ដល់ដល់អ្នកជាមួយនឹងព័ត៌មានចាំបាច់។

ច្បាប់តម្រូវឲ្យទីភ្នាក់ជួយរកការងារផ្ញើ ឲ្យផ្ដល់ដល់អ្នកនូវសេចក្ដីជូនដំណឹងជាអក្សរលាយលក្ខណ៍ ជាមួយនឹងព័ត៌មានចាំបាច់ អំពីការងារណា ដែលពួកគេកំពុងតែបញ្ជូនអ្នកទៅ។ នេះគឺត្រូវបានហៅថា បញ្ជាការងារ ។ អ្នកមានឯកសិទ្ធិដើម្បីនឹងប្រាប់ទីភ្នាក់ងារជួយរកការងារ ឲ្យផ្ដល់ដល់អ្នកនូវបញ្ជាការងារ ដូចជាតាមរយៈអ៊ីមែល សំបុត្រ ឬប្រសិនបើអ្នកត្រុវតែទៅយកបញ្ជានោះដោយផ្ទាល់។ ទីភ្នាក់ងារ ត្រូវតែ ផ្ដល់ដល់អ្នក យ៉ាងហោចណាស់នូវព័ត៌មាននេះៈម៉

- ឈ្មោះ, អសយដ្ឋាន និងលេខទូរស័ព្ទនៃ ៖ **(I)** ទីភ្នាក់ងារជួយដាក់កម្មករ; **(ii)** ការដឹកជញ្ជូនសំណងកម្មករ; **(iii)** នយោជកកន្លែងធ្វើ ការ; និង **(iv)** នាយកដ្ឋាន **(DLS)** ។
- ពិពណ៌នាការងារ ហើយថ្វីបើមុខងារនឹងតម្រូវនូវសម្លៀកបំពាក់ បរិក្ខា ការបង្វឹកបង្វឹន ឬអាជ្ញាបនប័ត្រ ពិសេស;
- ថ្ងៃបើកប្រាក់ អាត្រាឈ្នួលមួយម៉ោង ហើយថ្វីបើការឲ្យ ប្រាក់ចំពោះការធ្វើការលើសម៉ោង អាចកើតឬអត់;
- កាលបរិច្ឆេទចាប់ផ្ដើម ពេលចូលធ្វើការ និងពេលរំពឹង ចេញពីធ្វើការប្រចាំថ្ងៃ ហើយប្រសិនអាចដឹង អំឡុងពេលនៃការងារតម្រូវឲ្យធ្វើ;
- ថ្វីបើមានការដឹកជូន ឬអាហារដែលនឹងត្រូវបានផ្ដល់ឲ្យ ដោយទីភ្នាក់ជួយដាក់កម្មករ ឬនយោជកនៅកន្លែងធ្វើ ការឬអត់;
- ប្រសិនបើមានការគិតថ្លៃចំពោះនិយោជិត ឬកម្មករឬអត់;
- ថ្វីបើទីកន្លែងធ្វើការ មានកូដកម្ម ឬបិទទ្វារ; ហើយនិង
- សេចក្ដីថ្លែងការសម្រាប់ពហុវប្បធម៌ ដែលថាបញ្ជាការងារ មាននូវព័ត៌មានសំខាន់ពាក់ព័ន្ធនឹងការងារ នយោជិក ការចូលអនុវត្ត ភារកិច្ចការងារ ឬការងារ ។

ទីភ្នាក់ងារជួយរកការងារ អាចផ្ដល់ដល់អ្នកនូវព័ត៌មានការងារ តាមរយៈទូរស័ព្ទ ប៉ុន្ដែគេត្រូវតែ ផ្ញើដល់អ្នកនូវព័ត៌មានក្នុងអក្សរលាយលក្ខណ៍ មុននឹងចុងកំឡុងពេលបង់ប្រាក់
ឈ្នួល។

ប្រសិនបើការកំណត់ការងាររបស់អ្នកផ្លាស់ប្ដូរ ទីភ្នាក់ងារជួយរកការងារ ត្រូវតែ ប្រាប់អ្នកអំពីការផ្លាស់ប្ដូរទាំងនេះ យ៉ាងឆាប់រហ័សក្នុងពេលគេដឹងអំពីការផ្លាស់ប្ដូរទាំងនេះ។

បើទីភ្នាក់ងារជួយរកការងារ មិនផ្ដល់ដល់អ្នកជាមួយនឹងបញ្ជាការងារ ហើយអ្នកចង់ធ្វើការតវ៉ាជំទាស់នឹងទីភ្នាក់ងារជួយរកការងារ សូមទូរសព្ទទីក្រសួងបទដ្ឋានថាមពលការងារលេខ (617) 626-6969។ ទីភ្នាក់ងារជួយរកការងារមិនអាចបណ្ដេញអ្នក ឬផ្ដល់ដល់អ្នកនូវការងារដ៏អាក្រក់បំផុត ពីព្រោះតែលអ្នកតវ៉ាឡើយ។

ប្រសិនបើអ្នកត្រូវបានដាក់ក្នុងមុខងារវិជ្ជាជីវៈ ឬជាលេខាធិការ ឬអ្នកជំនួយរដ្ឋបាល ទីភ្នាក់ងារជួយរកការងារ មិនចាំបាច់ផ្ដល់អ្នកនូវបញ្ជា ការងារឡើយ។

## ទីភ្នាក់ងារជួយរកការងារនិងទីកន្លែងធ្វើការនយោជកមិនអាចទាកម្រៃពីអ្នកចំពោះ:

- ការចុះឈ្មោះជាមួយទីភ្នាក់ងារជួយរកការងារឡើយ;
- ផ្ដល់ការកំណត់ការងារដល់អ្នក;
- តេស្តរកគ្រឿងញៀន បណ្ណធនាគារ បណ្ណតណពន្ធ បណ្ណសំណង ឬប្រាក់លំដាប់;
- ធ្វើការឆែករកបញ្ជីព័ត៌ប្រវត្តអ្នកបំពានលើច្បាប់រដ្ឋម៉ាសាឈូសេត (CORI) ឡើយ;
- សេវាដឹកជូន ប្រសិនបើការប្រើសេវានោះត្រូវការចាំបាច់; ប្រសិនបើការប្រើសេវាដឹកជូននោះ ធ្វើឡើងដោយស្ម័គ្រចិត្តវិញនោះ ប្រាក់កម្រៃមិនអាចមានចំនួនហួសពី 3% នៃប្រាក់ឈ្នួលប្រចាំថ្ងៃ ឬ ថ្លៃពិត គឺថាវិធីណាមួយដែលថោកជាង;
- ឧបករណ៍ឬសេវាកម្មណា, រួមជាមួយរថយន្ត, ដែលនឹងធ្វើឲ្យអ្នករកបានលុយឈ្នួលតិចជាប្រាក់ឈ្នួលចំនួនតិចបំផុត នៃរដ្ឋម៉ាសាឈូសេតឡើយ;
- ទីភ្នាក់ងារជួយរកការងារ ឬទីកន្លែងធ្វើការរបស់នយោជក មិនអាចបង្ខំអ្នកឲ្យទិញអ្វីពីគេ លើកលែងតែអ្នកចង់ទិញប៉ុណ្ណោះ។
- ខុសច្បាប់ឯកសិទ្ធិអ្នកធ្វើការបណ្ដោះអាសន្នដើម្បីយល់ ដឹង **(Temporary Worker Right to Know Law)** ច្បាប់ប្រាក់ ឈ្នួលរដ្ឋម៉ាស្សាជូសេ្សត **(Massachusetts Wage Act)** ជា ទូទៅហាមប្រាមនូវកិច្ចព្រមព្រៀងណា ដែលនៅក្នុងកត្តានោះ នយោជកមានទំនួលខុសត្រូវចំពោះតម្លៃ និងការចំណាយទៅលើពាណិជ្ជកម្មសមញ្ញ ឡើយ ។ ជាលទ្ធផល គ្មានការកាត់បន្ថយប្រាក់ឈ្នួល ត្រូវបាន អនុញ្ញាតឲ្យធ្វើ លើកលែងតែគោលបំណងចម្បងរបស់វាគឺសម្រាប់អត្ថប្រយោជន៍របស់និយោជិត (ដូចជាការ ចំណាយដែលចំនួនច្រើន ចំពោះនិយោជិត និងត្រូវអាច យកមកប្រើដោយនិយោជិតនោះដោយមិនជាប់ពាក់ព័ន្ធនឹងការងារដែលខ្លួនបានធ្វើ) ។

ទីភ្នាក់ងារត្រូវតែផ្ដល់ប្រាក់សំណងចំពោះការចាយវាយទៅលើរថយន្តសមហេតុផលរបស់អ្នក ប្រសិនបើពួកគេបញ្ជូន អ្នកទៅការងារ ដែលពុំមានឡើយ។

នេះមិនរួមជាមួយតម្លៃរថយន្ត ដែលត្រូវបានបញ្ជូនទៅកន្លែងធ្វើការ សម្រាប់ការសម្ភាសន៍ការងារឡើយ។

## ទីភ្នាក់ងារជួយរកការងារមិនអាច:

- ផ្ដល់ដោយចេតនានូវព័ត៌មានក្លែងក្លាយ បោកប្រាស់ ឬខុសឆ្គងដល់អ្នកឡើយ;
- បង្ខំអ្នកឲ្យទៅកណត់ការងារ ដែលអ្នកមិនចង់ទៅនោះឡើយ;
- លាក់ទុក និងបដិសេធរបស់របររបស់អ្នកដោយមិនប្រគល់ឲ្យអ្នកឡើយ;
- លាក់ទុកប្រាក់កម្រៃខុសច្បាប់ ដែលពួកគេបានទាពីអ្នកឡើយ;
- បណ្ដេញអ្នកឬផ្ដល់ដល់អ្នកនូវការងារអាក្រក់បំផុត ពីព្រោះតែអ្នកប្រតិបត្តិឯកសិទ្ធិរបស់អ្នកក្រោមច្បាប់នេះឡើយ;
- បញ្ជូនអ្នកទៅកំណត់ការងារ ដើម្បីនឹងធ្វើការដែលខុសនឹងច្បាប់ឡើយ;
- បញ្ជូនក្មេងក្រោមអាយុទៅកំណត់ការងារ នៅពេលដែលក្មេងគប្បីនៅឯសាលារៀនឡើយ;
- បញ្ជូនអ្នកទៅកណត់ការ ជាទីកន្លែងដែលតម្រូវឲ្យមានអាជ្ញាប័ណ្ណពិសេស ប្រសិនបើអ្នកពុំមានអាជ្ញាប័ណ្ណនោះឡើយ;

សម្រាប់ព័ត៌មានបន្ថែមបន្ថែមអំពីអំពីឯកសិទ្ធអ្នកធ្វើការបណ្ដោះអាសន្ន ដើម្បីដឹងអំពីច្បាប់ ឬដើម្បីធ្វើការតវ៉ា សូមទូរស័ព្ទក្រសួងបដ្ឋានថាមពលការងារ លេខ **(617) 626-6969**, ឬចូលទៅ **mass.gov/dols/epsap**។ ច្បាប់នេះគឺត្រូវបានចាត់ចែងដោយក្រសួងបទដ្ឋានថាមពលការងារ (DLS) និងត្រូវបាន ប្រតិបត្តិ ដោយក្រសួង Attorney General's Fair Labor Division។ ច្បាប់នេះអាចអនុវត្តចំពោះ "ទីភ្នាក់ងារជួយរកការងារ" (ឧទាហរណ៍ ទីភ្នាក់ងារបណ្ដោះអាសន្ន) ចង្អុលបង្ហាញដោយច្បាប់។

សេចក្ដីជូនដំណឹងចំពោះកន្លែងធ្វើការ: សេចក្ដីជូនដំណឹងកន្លែងធ្វើការនេះអនុវត្តជាមួយនឹងការផ្ដល់នៃច្បាប់ទូទៅនៃរដ្ឋម៉ាសាឈូសេត កថាខណ្ឌ 149, ភាគ 159C, ដែលតម្រូវថាទីភ្នាក់ងារជួយរកការងារដាក់តាំង ក្នុងទីកន្លែងដែលដាក់ពាក្យសុំការងារ ឬកម្មករអាចមើលឃើញយ៉ាងស្រួល។